ឆ្នាំ២០១៤

# មេរៀនស្តីពី

# សិទ្ធិដីធ្លីក្នុងច្បាប់ភូមិបាលឆ្នាំ២០០១



បោះពុម្ពដោយ

ឧបត្ថម្ភដោយ

សហការចងក្រងដោយ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

icco

OPEN SOCIETY
FOUNDATIONS

CLEC

# អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិកម្ពុជា ("ម.ស.ម.ក") ជាអង្គការមិនមែនរដ្ឋាភិបាល មិនចូលបក្សសម្ព័ន្ធ ឯករាជ្យដែលធ្វើការដើម្បីលើកកំពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ចក្ខុវិស័យរបស់ ម.ស.ម.ក ចង់ឲ្យកម្ពុជាក្លាយជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលក្នុងនោះប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសមភាព ត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍប្រទេស។ ម.ស.ម.ក. ចង់បាននីតិរដ្ឋជាជាងនិទណ្ឌភាព ចង់បានស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងចង់បានសង្គមពហុនិយមដោយក្នុងនោះភាពចម្រុះបែបនៃសង្គមត្រូវបានទទួលយក និងសាទរជាជាងព្រងើយកន្តើយ ឬដាក់ទណ្ឌកម្ម។ ស្លាកសញ្ញារបស់ ម.ស.ម.ក រំលេចឲ្យឃើញរូបសត្វព្រាបសហើរចេញពីរង្វង់មូលនៃផ្ទៃមេឃពណ៌ខៀវ ដែលនេះជានិមិត្តរូបនៃការទាមទារសេរីភាពរបស់កម្ពុជា។

សៀវភៅមេរៀនស្តីពី "**សិទ្ធិដីធ្លីក្នុងច្បាប់ភូមិបាល ២០០១**" ត្រូវបានចងក្រងឡើងក្នុងខណៈដែលទំនាស់ដីធ្លីកំពុងតែរីករាលដាលនៅកម្ពុជា ដែលបណ្តាលឲ្យប្រជាពលរដ្ឋរាប់សែននាក់រងផលប៉ះពាល់ក្លាយទៅជាអ្នកគ្មានដី និងផ្ទះ អ្នកចំណាកស្រុក និងជាអ្នកមានទំទាស់លើដីរបស់ខ្លួនឯង ដោយសារតែកម្មវិធីអភិវឌ្ឍន៍តាមរយៈការធ្វើសម្បទានដីរបស់រដ្ឋដោយពុំមានតម្លាភាពភាព គណនីយភាព និងភាពស្របច្បាប់ ព្រមទាំងកង្វះខាតក្នុងការយល់ដឹងអំពីច្បាប់ និងការតស៊ូមតិរបស់ប្រជាពលរដ្ឋ។

សៀវភៅមេរៀនស្តីពី "**សិទ្ធិដីធ្លីក្នុងច្បាប់ភូមិបាល ២០០១**" ជាមគ្គុទេសក៍សម្រាប់ប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ដោយសារទំនាស់ដីធ្លី យល់ដឹងអំពីភាពស្របច្បាប់ និងភាពមិនស្របច្បាប់ក្នុងការកាន់កាប់ដី និងផ្ទះរបស់ខ្លួនដើម្បីធ្វើសេចក្តីសម្រេចចិត្តដ៏ត្រឹមត្រូវឈានដល់ការធ្វើការតស៊ូមតិដោយអហិង្សាប្រកបដោយការគាំទ្រដើម្បីការពារដី និងផ្ទះ និងទាមទារដី និងផ្ទះស្របច្បាប់របស់ខ្លួនដែលកំពុងប្រឈម និងត្រូវបានរឹបអូសយក។

## សេចក្ដីថ្លែងអំណរគុណ

សៀវភៅមេរៀនស្ដីពី "សិទ្ធិដីធ្លីក្នុងច្បាប់ភូមិបាល២០០១" កើតជារូបរាងឡើងបាន ដោយសារកិច្ចឧបត្ថម្ភគាំទ្ររបស់សហភាពអឺរ៉ុប ("EU") មូលនិធិសង្គមបើកទូលាយ ("OSF") និងអង្គការអន្តរព្រះវិហារសម្រាប់សហប្រតិបត្តិការការងារអភិវឌ្ឍន៍ ("ICCO")។

ខ្លឹមសារនៃសៀវភៅមេរៀននេះគឺជាការទទួលខុសត្រូវទាំងស្រុងរបស់ ម.ស.ម.ក និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប មូលនិធិសង្គមបើកទូលាយ និងអង្គការអន្តរព្រះវិហារសម្រាប់សហប្រតិបត្តិការការងារអភិវឌ្ឍននោះទេ។ ម.ស.ម.ក ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ ដែលបានចូលរួមសហការចងក្រងសៀវភៅមេរៀននេះឡើង។

## ចម្ងល់ និងមតិចូលរួម

ប្រសិនបើលោកអ្នកមានសំណួរ ឬត្រូវការព័ត៌មានបន្ថែមពាក់ព័ន្ធនឹងសៀវភៅមេរៀននេះ ឬមានបំណងចង់ផ្ដល់ជាមតិយោបល់ សូមសរសេរមកកាន់ម.ស.ម.ក តាមរយៈអ៊ីម៉ែល info@cchrcambodia.org ។ ម្យ៉ាងទៀត លោកអ្នកអាចទាក់ទងម.ស.ម.ក តាមរយៈ ៖

អាសយដ្ឋាន៖ ផ្ទះលេខ៧៩៨ ផ្លូវ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

អ៊ីមែល ៖ info@cchrcambodia.org

ទូរស័ព្ទ ៖ ៨៥៥ (០) ២៣ ៧២៦ ៩០១

ទូរសារ ៖ ៨៥៥ (០) ២៣ ៧២៦ ៩០១

វែបសាយ ៖ www.cchrcambodia.org

រូបគម្របមុខ ៖ ទីតាំងដីមួយកន្លែងនៅខេត្តឧត្តរមានជ័យ។ រូបភាពថតដោយ ម.ស.ម.ក

(cc) CCHR

# មាតិកា


១. សេចក្តីផ្តើម ........ ១

២ .ការធ្វើចំណាត់ថ្នាក់ដីធ្លី........ ១

២.១ .ដីសាធារណៈរបស់រដ្ឋ........២

២.១.១ .និយមន័យ ........ ២

២.១.២ .ប្រភេទដីសាធារណៈរបស់រដ្ឋ ........ ២

២.១.៣ .សិទ្ធិលើដី/ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ........៣

២.២ .ដីឯកជនរបស់រដ្ឋ........ ៣

២.២.១ .និយមន័យ ........៣

២.២.២ .សិទ្ធិលើដីឯកជនរបស់រដ្ឋ........៣

២.២.៣ .ការហាមឃាត់សិទ្ធិលើដីឯកជនរបស់រដ្ឋ........៣

២.៣ .ដីរបស់ឯកជន/បុគ្គល........៤

២.៣.១ .និយមន័យ........៤

២.៣.២ .សិទ្ធិលើដីឯកជន ឬបុគ្គល ........៤

៣ .លទ្ធកម្មនៃកម្មសិទ្ធិ ........៤

៣.១ .ភោគៈត្រឹមត្រូវតាមច្បាប់ ........ ៤

៣.១.១ .តើភោគៈជាអ្វី? ........៤

៣.១.២ .តើភោគីជាអ្វី?........៥

៣.១.៣ .តើភោគៈយ៉ាងម៉េចដែលអាចប្រែក្លាយទៅជាកម្មសិទ្ធិស្ពាពរបាន? ........៥

៣.១.៤ .តើមានលក្ខខណ្ឌអ្វីខ្លះដើម្បីបានភោគៈស្របច្បាប់ (ភោគៈត្រឹមត្រូវតាមច្បាប់)........៥

៣.១.៥ .សិទ្ធិលើដីភោគៈ........ ៦

៣.១.៦ .ការដកហូតដីភោគៈដោយរដ្ឋ ........ ៧

៣.២. សម្បទានដីសង្គមកិច្ច ........................................................................................ ៧
៣.២.១ .និយមន័យ ........................................................................................ ៧
៣.២.២ .ប្រភេទដីដែលអាចធ្វើសម្បទានសង្គមកិច្ច ........................................................ ៧
៣.២.៣ .សិទ្ធិលើសម្បទានដីសង្គមកិច្ច ........................................................................ ៧
៣.២.៤ .កម្មវិធីសម្បទានដីសង្គមកិច្ច ........................................................................ ៨
៣.២.៤.១ .កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ............................................ ៨
៣.២.៤.២ .កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ .................................................. ៨
៤ .សម្បទានដីសេដ្ឋកិច្ច ........................................................................................ ៩
៤.១ .និយមន័យសម្បទានដីសេដ្ឋកិច្ច ........................................................................ ៩
៤.២ .គោលបំណងការធ្វើសម្បទានដីសេដ្ឋកិច្ច ............................................................ ១០
៤.៣ .លក្ខខណ្ឌសម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច ..................................................... ១០
៤.៤ .ការដកហូត និងការកាត់បន្ថយសម្បទានដីសេដ្ឋកិច្ច ............................................... ១២
៤.៥ .យន្តការដាក់ពាក្យបណ្តឹងទាក់ទងការផ្តល់សម្បទានដីសេដ្ឋកិច្ច ................................... ១៣
៤.៦ .របៀបសរសេរពាក្យបណ្តឹង ............................................................................ ១៤
៤.៦.១ .របៀបសរសេរពាក្យបណ្តឹងទៅគណៈកម្មការសុរិយោដី ........................................ ១៥
៤.៦.២ .របៀបសរសេរពាក្យបណ្តឹងទៅតុលាការ ............................................................ ១៧

# ១. សេចក្តីផ្តើម

ច្បាប់ភូមិបាលបានប្រកាសប្រើនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។ ច្បាប់នេះមានគោលដៅកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងគោលបំណងធានាការពារសិទ្ធិនៃកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុស្របតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា។

ច្បាប់ភូមិបាលនេះក៏បានកំណត់បង្ហាញអំពីការធ្វើចំណាត់ថ្នាក់ដីលទ្ធកម្ម[1]នៃកម្មសិទ្ធិ និងការផ្តល់ដីសម្រាប់សម្បទានដីសេដ្ឋកិច្ច និងសង្គមកិច្ចផងដែរ។

# ២. ការធ្វើចំណាត់ថ្នាក់ដីធ្លី

បើយោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ នៅក្នុងប្រទេសកម្ពុជា ដីត្រូវបានបែងចែកជាប្រភេទដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ ដីឯកជន(ដីរបស់បុគ្គលម្នាក់ ឬច្រើននាក់) ដីរបស់សហគមន៍ជនជាតិដើមភាគតិច និងដីរបស់វត្ត។

ប្រភេទដីនីមួយៗមានការកំណត់ច្បាស់ថា តើអ្នកណាខ្លះអាចកាន់កាប់បាន ហើយកាន់កាប់ក្នុងគោលបំណងអ្វី ។




[1]លទ្ធកម្ម គឺការបានឡើងជាភោគី ឬជាកម្មសិទ្ធករនៃវត្ថុណា ដោយការងាររបស់ខ្លួនក្តី ដោយទិញក្តី ដោយដូរក្តី ដោយសន្តតិកម្មក្តី(សន្តតិកម្ម គឺការផ្ទេរតាមច្បាប់នូវទ្រព្យសម្បត្តិរបស់អ្នកស្លាប់ទៅឲ្យអ្នករស់) ។

## ២.១ .ដីសាធារណៈរបស់រដ្ឋ

### ២.១.១. និយមន័យ

ដីសាធារណៈរបស់រដ្ឋ ជាដីសម្រាប់បំរើដល់ផលប្រយោជន៍សាធារណៈ។

### ២.១.២. ប្រភេទដីសាធារណៈរបស់រដ្ឋ

តាមមាត្រា១៥ នៃច្បាប់ភូមិបាលបានចែងរៀបរាប់អំពីដី និងទ្រព្យដែលចាត់ចូលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមានដូចជា ៖

- ទ្រព្យទាំងឡាយដែលបង្ហាញនូវការកើតឡើងពីធម្មជាតិដូចជា ព្រៃឈើ ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន បឹងធម្មជាតិ ច្រាំងទន្លេដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន និងត្រើយសមុទ្រ។
- ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសំរាប់ប្រយោជន៍ទូទៅដូចជា កំពង់ផែ ផ្លូវដែក ស្ថានីយរថភ្លើង និងព្រលានយន្តហោះ។
- ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឲ្យប្រើប្រាស់ជាសាធារណៈតាមស្ថានភាពពីកំណើត ឬក្រោយពីការរៀបចំដូចជាផ្លូវថ្នល់ ផ្លូវលំ ផ្លូវរទេះ ផ្លូវដើរ សួនច្បារ និងឧទ្យានសាធារណៈ និងដីចំណីផ្លូវ។
- ទ្រព្យទាំងឡាយ ដែលត្រូវបានដាក់ឲ្យដំណើរការណ៍សេវាសាធារណៈដូចជា សាលារៀន ឬអគារសិក្សាសាធារណៈ អគាររដ្ឋបាល មន្ទីរពេទ្យសាធារណៈទាំងឡាយ ។
- ទ្រព្យទាំងឡាយដែលបង្កើតជាដែនបំរុងធម្មជាតិការពារដោយច្បាប់។
- បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ។
- អចលនវត្ថុជាព្រះរាជទ្រព្យដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស។ អចលនវត្ថុជាព្រះរាជទ្រព្យត្រូវបានចាត់ចែងដោយព្រះមហាក្សត្រកំពុងគ្រងរាជ្យ។
- ដីផ្សេងៗទៀតដែលមានចរិតបំរើផលប្រយោជន៍សាធារណៈ និងមានមូលដ្ឋានច្បាប់កំណត់ហើយដូចជា ប្រឡាយបង្ហូរទឹកសំរាប់ស្រោចស្រពស្រែចំការ ឬបង្ហូរទឹកដែលបានប្រើប្រាស់ហើយ (ក្នុងមាត្រា៩ នៃអនុក្រឹត្យការគ្រប់គ្រងដីរដ្ឋ)។

### ២.១.៣. សិទ្ធិលើដី/ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ

- ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចលក់ដូរបានឡើយ។
- កម្មសិទ្ធនៃទ្រព្យសម្បត្តិទាំងនោះមិនអាចកំណត់អាជ្ញាយុកាល ប៉ុន្តែអាចជាកម្មវត្ថុនៃការអនុញ្ញាតអោយកាន់កាប់ ឬប្រើប្រាស់ជាបណ្តោះអាសន្នមិនទៀងហើយដកហូតវិញបាន។

*<u>សំគាល់</u>៖ នៅពេលបាត់បង់ផលប្រយោជន៍សាធារណៈ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋអាចត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ តាមរយៈច្បាប់អនុបយោគ។*

## ២.២ .ដីឯកជនរបស់រដ្ឋ

### ២.២.១. និយមន័យ

- មិនមែនជាដីសាធារណៈរបស់រដ្ឋ
- មិនមែនជាដីដែលកាន់កាប់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិឯកជន ឬសម្ហូហាភាព។
- ទ្រព្យនិទាឃាទភាព (គ្មានទាយាទបន្ត) ទាំងអស់។
- ទ្រព្យដែលម្ចាស់ប្រគល់អោយរដ្ឋដោយស្ម័គ្រចិត្ត។
- ទ្រព្យដែលមិនអាចកំណត់បាននូវអត្តសញ្ញាណភោគី ឬកម្មសិទ្ធិករស្របច្បាប់។
- ដីសាធារណៈរបស់រដ្ឋនៅពេលបាត់បង់ផលប្រយោជន៍សាធារណៈ អាចចាត់បញ្ចូលជាដីឯកជនរបស់រដ្ឋ ។

### ២.២.២. សិទ្ធិលើដីឯកជនរបស់រដ្ឋ

ដី ឬទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ រដ្ឋ ឬស្ថាប័នរដ្ឋអាចមានសិទ្ធិយកទៅធ្វើជាកម្មវត្ថុនៃការលក់ ការដូរ ការជួល ការបែងចែក ឬការផ្ទេរសិទ្ធិតាមការកំណត់ដោយច្បាប់។

### ២.២.៣. ការហាមឃាត់សិទ្ធិលើដីឯកជនរបស់រដ្ឋ

គ្មានការចូលទៅកាន់កាប់ ឬចាប់យកដីតាមទំនើងចិត្តណាមួយអាចកើតឡើងទៅលើដីឯកជនរបស់រដ្ឋបានឡើយចាប់ពីច្បាប់នេះចូលជាធរមានពីថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។

ប៉ុន្តែដីទំនេរនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ អាចត្រូវបានបែងចែកទៅឲ្យបុគ្គល ដែលត្រូវការដីនោះក្នុងគោលដៅសង្គមកិច្ច។

## ២.៣ .ដីរបស់ឯកជន/បុគ្គល

### ២.៣.១. និយមន័យ

ដីឯកជនជាដីកម្មសិទ្ធិ (អ្នកកាន់កាប់មានប័ណ្ណសម្គាល់កម្មសិទ្ធិស្របច្បាប់ជាផ្លូវការ) ឬជាដីភោគៈស្របច្បាប់(អ្នកកាន់កាប់អាចបង្ហាញភស្តុតាងថាពួកគាត់បានរស់នៅលើដីនោះតាំងពីមុនពេលច្បាប់ភូមិបាលចូលជាធរមាននៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ និងបង្ហាញ ថាពួកគាត់បានបំពេញលក្ខខណ្ឌ៥ យ៉ាងអំពីភោគៈស្របច្បាប់)។

### ២.៣.២. សិទ្ធិលើដីឯកជន ឬបុគ្គល

ដីកម្មសិទ្ធិឯកជនអាចជាកម្មសិទ្ធិរបស់បុគ្គលម្នាក់ ក្រុមហ៊ុន ឬកម្មសិទ្ធិរួមដែលមានគ្នាច្រើនលើសពីមួយនាក់ ឧទាហរណ៍ ប្តី និងប្រពន្ធ។ ហើយបុគ្គលដែលជាម្ចាស់កម្មសិទ្ធិលើដីនេះមានសិទ្ធិដូចជា សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និងសិទ្ធិចាត់ចែងនៅលើដី។

*<u>ចំណាំ</u> ៖ នៅក្នុងប្រភេទនៃការបែងចែកចំណាត់ថ្នាក់ដីក៏មានរាប់បញ្ចូលទាំងដីដែលគ្រប់គ្រង ដោយសហគមន៍ជនជាតិដើមភាគតិច និងដីដែលគ្រប់គ្រងដោយវត្តដែរ។*

# ៣. លទ្ធកម្មនៃកម្មសិទ្ធិ

លទ្ធកម្មនៃកម្មសិទ្ធិ គឺការទទួលបានកម្មសិទ្ធិ។

<u>តើពលរដ្ឋអាចទទួលបានកម្មសិទ្ធិដោយរបៀបណា?</u>

ច្បាប់ភូមិបាលឆ្នាំ២០០១ មិនបានកំណត់ពីបរិមាណ ឬទំហំដីសំរាប់ធ្វើជាកម្មសិទ្ធិឡើយ។ ប្រជាពលរដ្ឋគ្រប់រូបអាចមានសិទ្ធិទទួលបានកម្មសិទ្ធិស្របច្បាប់លើអចលនៈវត្ថុបានតាមរយៈ ការទិញ ភោគៈ សម្បទានដីសង្គមកិច្ច អំណោយ ។ល។

## ៣.១ .ភោគៈត្រឹមត្រូវតាមច្បាប់

### ៣.១.១. តើភោគៈជាអ្វី?

គឺជាសភាពការណ៍មួយដែលមានន័យថា កិរិយាកាន់កាប់នូវវត្ថុណាមួយយ៉ាងផ្តាច់មុខតែម្នាក់ឯង និងបំពេញចំពោះវត្ថុនោះនូវកិច្ចការទាំងឡាយដូចដែលកម្មសិទ្ធិករបានបំពេញហើយដែរ។ មានន័យថាដើម្បីមានភោគៈ បុគ្គលដែលជាអ្នកកាន់កាប់ត្រូវបង្ហាញថា ខ្លួន

កំពុងកាន់កាប់ដី ខ្លួនបានបំពេញភារៈជាកម្មសិទ្ធិករ ហើយមានបំណងចង់ក្លាយជាកម្មសិទ្ធិករ (តាមច្បាប់ភូមិបាលឆ្នាំ១៩៩២)។

- តាមច្បាប់ភូមិបាល ឆ្នាំ២០០១៖ ភោគៈគឺជាសិទ្ធិដែលជនម្នាក់ៗមានលើទ្រព្យណាមួយជាបណ្តោះអាសន្នមិនស៊ប់ជារបស់ខ្លួនមែនទែន។
  ឧទាហរណ៍៖ ដីមានប្លង់ជាកម្មសិទ្ធិ ឯដីមិនទាន់មានប្លង់សុរិយោដី ជាដីភោគៈ។

**សំគាល់៖ កម្មសិទ្ធិ និងភោគៈជាស្ថានភាពពីរខុសគ្នា៖**

- **ភោគៈ ៖ ជាស្ថានភាពកាន់កាប់ដោយយកសភាពការណ៍កាន់កាប់ជាសំអាង**
- **កម្មសិទ្ធិ៖ ជាស្ថានភាពគតិយុត្តិដោយយកច្បាប់ជាសំអាង**

### ៣.១.២. តើភោគីជាអ្វី?

ភោគី គឺជាអ្នកទទួលបានភោគៈ។

### ៣.១.៣. តើភោគៈយ៉ាងម៉េចដែលអាចប្រែក្លាយទៅជាកម្មសិទ្ធិស្ថាពរបាន?

- បានអាស្រ័យផលនៃភោគៈដោយសន្តិវិធី (ភោគៈត្រឹមត្រូវតាមច្បាប់)។
- បានកាន់កាប់កន្លងមកដោយមិនមានការជំទាស់ ចាប់ពីរយៈពេល៥ឆ្នាំយ៉ាងតិចគិតមកដល់កាលបរិច្ឆេទនៃការប្រកាសឲ្យប្រើច្បាប់នេះ។

### ៣.១.៤. តើមានលក្ខខណ្ឌអ្វីខ្លះដើម្បីបានភោគៈស្របច្បាប់ (ភោគៈត្រឹមត្រូវតាមច្បាប់)

- ការកាន់កាប់ដោយគ្មានហិង្សា (សន្តិវិធី ឬសន្តិភាព) គឺថាភោគៈដែលបានមកដោយហិង្សាមិនចាត់ទុកជាភោគៈត្រឹមត្រូវតាមច្បាប់ឡើយ។ ប៉ុន្តែបើកាលណាគេប្រើហិង្សាក្នុងពេលមានតតិយជនឥតសិទ្ធិសោះមកជណ្តើមនោះ ហិង្សានេះគ្មានឥទ្ធិពលអ្វីទៅលើភោគៈដែលគេបានដោយសន្តិភាពតាំងពីដើមមកនោះទេ។
- ការកាន់កាប់ដោយសុច្ចរិត គឺថាភោគីមិនដឹងពីសិទ្ធិជាយថាហេតុរបស់តតិយជនលើវត្ថុដែលខ្លួនកំពុងកាន់កាប់នោះសោះ។
- ការកាន់កាប់ដោយពិតប្រាកដ (ច្បាប់ពីដើមប្រើពាក្យ"ឥតព្រលាំ") គឺថាភោគីនោះកាន់កាប់ដោយខ្លួនឯងក្តី ឲ្យអ្នកដទៃធ្វើឲ្យក្តី ត្រូវកាន់កាប់ឲ្យឃើញថាការនោះប្រាកដជាធ្វើដើម្បីខ្លួនក្នុងគោលបំណងខ្លួនជាភោគីយ៉ាងផ្តាច់មុខ កុំឲ្យឃើញថាការដែលធ្វើនោះ គឺធ្វើដោយសារសិទ្ធិណាមួយផ្សេងទៅវិញ។ ប្រសិនបើភោគីពិតប្រាកដ

មិនចេញមុខ មានន័យថាគាត់នៅពីក្រោយភោគីមិនពិតប្រាកដ ភោគីនោះមិនអាចទាមទារប័ណ្ណភោគៈដើម្បីធ្វើលទ្ធកម្មទៅជាកម្មសិទ្ធិបានឡើយ (ភោគៈនោះត្រូវចាត់ទុកជាមោឃៈ)។

- ការកាន់កាប់ដោយការដឹងឮជាសាធារណៈ គឺថាភោគីត្រូវកាន់កាប់ដោយឥតលាក់បិទបាំងអ្នកទាំងពួងដែលចង់តវ៉ាអំពីសិទ្ធិរបស់ខ្លួនលើវត្ថុនោះនឹងបានដឹងឮឃើញមិនខាន។(បានឃើញថាមិនអខាន)
- ការកាន់កាប់ដោយគ្មានការអាក់ខាន (ច្បាប់ពីដើមប្រើពាក្យ"ជានិរន្តរ") គឺថាភោគីត្រូវធ្វើនូវកិច្ចការផងទាំងពួងតាមធម្មតាជាប្រក្រតីក្នុងរយៈពេលចាំបាច់នៃការទាមទារលទ្ធកម្មកម្មសិទ្ធិ។ ការអាក់ខានក្នុងរយៈពេលខ្លី ឬបោះបង់ទុកឲ្យនៅទំនេរដើម្បីឲ្យមានជីវជាតិឡើងវិញមិនមែនជាឧបសគ្គដល់លទ្ធកម្មកម្មសិទ្ធិនោះទេ។

*<u>ចំណាំ</u> ៖*

- *ការចូលកាន់កាប់ភោគៈ ត្រូវបញ្ចប់ ចាប់ពីច្បាប់ភូមិបាលចូលជាធរមាន នៅថ្ងៃទី៣០ ខែ សីហា ឆ្នាំ ២០០១។*

## ៣.១.៥. សិទ្ធិលើដីភោគៈ

តើភោគីមានសិទ្ធិអ្វីខ្លះលើដីរបស់ខ្លួន? ភោគីមានសិទ្ធិលើដីប្រហែលនឹងកម្មសិទ្ធិករដែរគឺ៖



### ៣.១.៦. ការដកហូតដីភោគៈដោយរដ្ឋ

ក្នុងករណី បើមានការដកហូតដីភោគៈដោយអាជ្ញាធរណាមួយ ដោយប្រើអំណាចរំលោភ ឬដោយហឹង្សា ម្ចាស់ដីភោគៈ(ភោគី)មានសិទ្ធិប្ដឹងទាមទារដីត្រឡប់មកវិញក្នុងរយៈពេល៣ឆ្នាំចាប់ពីថ្ងៃដែលរដ្ឋប្រកាសដកហូត។ ដីភោគៈដែលរដ្ឋដកហូតនោះត្រូវទុកក្នុងការកាន់កាប់ដោយរដ្ឋ ហើយមិនអាចជាកម្មវត្ថុនៃការកាន់កាប់ថ្មីបានឡើយបើគ្មានបណ្ដឹងទាមទារពីភោគីស្របច្បាប់នៃដីនោះ (មាត្រា ៣៣)។

ចំពោះដីកាន់កាប់ដោយភោគីស្របច្បាប់ នៅពេលមានការដកហូតដោយរដ្ឋដើម្បីបំរើផលប្រយោជន៍សាធារណៈរដ្ឋត្រូវធ្វើការផ្ដល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។

## ៣.២. សម្បទានដីសង្គមកិច្ច

### ៣.២.១. និយមន័យ



សម្បទានដីសង្គមកិច្ច គឺជាយន្តការនៃការផ្ទេរដីឯកជនរបស់រដ្ឋតាមផ្លូវច្បាប់ក្នុងគោលបំណងផ្ដល់ជាសង្គមកិច្ចដល់ជនក្រីក្រដែលខ្វះខាតដីសម្រាប់សង់លំនៅដ្ឋាន ឬនិងធ្វើកសិកម្មជាលក្ខណៈគ្រួសារ។

### ៣.២.២. ប្រភេទដីដែលអាចធ្វើសម្បទានសង្គមកិច្ច

សម្បទានដី អាចធ្វើឡើងបានតែនៅលើដីដែលជាចំណែកនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋតែប៉ុណ្ណោះ។

### ៣.២.៣. សិទ្ធិលើសម្បទានដីសង្គមកិច្ច

អ្នកដែលជាមុខសញ្ញាទទួលបាននូវសម្បទានដីសង្គមកិច្ចមាន គ្រួសារក្រីក្រដែលគ្មានទីលំនៅ និងគ្មានដីកសិកម្មលក្ខណៈគ្រួសារ គ្រួសារដែលត្រូវផ្លាស់ប្តូរទីលំនៅបណ្តាលមកពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ គ្រួសារដែលរងគ្រោះដោយគ្រោះធម្មជាតិ គ្រួសារមាតុភូមិនិវត្តន៍ យោធិនរំសាយ និងគ្រួសារយុទ្ធជនពលីពិការ ។ល។

អ្នកទទួលសម្បទានដីនេះ អាចទទួលបានប័ណ្ណកម្មសិទ្ធិលើដីករណី ដែលអ្នកទទួលសម្បទានដីនេះបំពេញបាននូវលក្ខខណ្ឌ ដែលបានកំណត់មានលក្ខខណ្ឌកាន់កាប់ដី (ត្រូវទៅរស់នៅ ឬទាញយកផលពីដី) និងលក្ខខណ្ឌរយៈពេល(៥ឆ្នាំ)។

ក្នុងករណីអ្នកទទួលសម្បទានដីទទួលមរណៈភាពនៅក្នុងរយៈពេលកំពុងអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ទាយាទ(កូន) ក្នុងគ្រួសារនៃអ្នកទទួលសម្បទានដីនោះអាចបន្តអនុវត្តដីសង្គមកិច្ចនេះរហូតដល់គ្រប់៥ឆ្នាំ ហើយមានសិទ្ធិកម្មសិទ្ធិលើដីនោះ។

អ្នកទទួលសម្បទានដីមិនអាចលក់ដូរ ជួល ឬ ធ្វើអំណោយសម្បទានដីសង្គមកិច្ចក្នុងរយៈពេល ៥ ឆ្នាំដំបូងនៃការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចនេះទេ។

### ៣.២.៤. កម្មវិធីសម្បទានដីសង្គមកិច្ច

កម្មវិធីសម្បទានដីសង្គមកិច្ចមានពីរ ៖

#### ៣.២.៤.១. កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន

- ក្រុមប្រឹក្សាឃុំជាអ្នកផ្តួចផ្តើមកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានសំរាប់បែងចែកដីដល់អ្នកក្រីក្រ។ នៅពេលដែលមើលឃើញថាដីនៅក្នុងឃុំរបស់ខ្លួននៅមានដីទំនេរ (ហើយជាដីឯកជនរបស់រដ្ឋ)។
- ប្រជាពលរដ្ឋម្នាក់ ឬច្រើននាក់ ឬអង្គការដែលធ្វើការជាមួយប្រជាពលរដ្ឋ ឬតំណាងប្រជាពលរដ្ឋនៃឃុំសង្កាត់នោះ ក៏អាចផ្តួចផ្តើមកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានបានដែរ។ ប៉ុន្តែត្រូវធ្វើតាមរយៈក្រុមប្រឹក្សាឃុំសង្កាត់ដែលដីសម្បទានសង្គមកិច្ចនោះស្ថិតនៅ។

#### ៣.២.៤.២. កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

- កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អាចត្រូវបានផ្តួចផ្តើមឡើងដោយក្រសួងស្ថាប័នពាក់ព័ន្ធមួយ ឬច្រើនក្នុងស្ថានភាព ដែលកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានមិនអាចធ្វើបាន និងក្នុងស្ថានភាពពិសេសដូចជា ៖
- កន្លែងដែលមានកម្មវិធីអភិវឌ្ឍន៍ដីនៅតំបន់ដាច់ស្រយាល ដែលពុំទាន់មានប្រជាពលរដ្ឋមូលដ្ឋានគ្រប់គ្រាន់ដើម្បីអភិវឌ្ឍដីនោះ។
- កន្លែងដែលមានកម្មវិធីតាំងទីលំនៅថ្មីសម្រាប់គ្រួសារច្រើនដូចជាករណីដំណោះស្រាយសំណាងបណ្តោះអាសន្ននៅតាមទីប្រជុំជន ឬគ្រួសារដែលត្រូវផ្លាស់ប្តូរទីកន្លែង។
- កន្លែងដែលកម្មវិធីសម្បទានដីសង្គមកិច្ចអាចផ្សារភ្ជាប់ទៅនឹងសម្បទានដីសេដ្ឋកិច្ចដើម្បីអភិវឌ្ឍកសិ-ឧស្សាហកម្ម។
- កន្លែងដែលមានកម្មវិធីអភិវឌ្ឍន៍ថ្មី ឬមានកម្មវិធីអភិវឌ្ឍន៍ស្រាប់ ដែលត្រូវសម្របសម្រួលដោយថ្នាក់ជាតិដូចជាកម្មវិធីដែលគាំទ្រដោយអ្នកផ្តល់ជំនួយ ឬអ្នកវិនិយោគ។
- កន្លែងដែលតម្រូវឲ្យមានសម្បទានដីសង្គមកិច្ច ដែលថ្នាក់មូលដ្ឋានមិនអាចធ្វើកម្មវិធីសម្បទានបាន។

# ៤. សម្បទានដីសេដ្ឋកិច្ច

នៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ និងអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០០៥ បានចែងអំពីទំហំដី ប្រភេទដីក្របខ័ណ្ឌក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចទៅឲ្យក្រុមហ៊ុន (នីតិបុគ្គលស្របច្បាប់) និងសិទ្ធិរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានពាក់ព័ន្ធនឹងការផ្តល់សម្បទានដីសេដ្ឋកិច្ច។



## ៤.១ .និយមន័យសម្បទានដីសេដ្ឋកិច្ច

សម្បទានដីសេដ្ឋកិច្ច មានន័យសំដៅដល់សម្បទានមួយដាក់លាក់ទៅឲ្យសម្បទានិក ដើម្បីប្រើប្រាស់សម្រាប់ធ្វើអាជីវកម្មកសិកម្ម និងកសិ-ឧស្សាហកម្ម។

<u>**ការធ្វើអាជីវកម្មកសិ-ឧស្សាហកម្មសំដៅដល់ ៖**</u>

- ការដាំដំណាំស្បៀង ឬដំណាំឧស្សាហកម្មរាប់ទាំងការដាំដើមឈើជាចំការឈើ
- ការចិញ្ចឹមសត្វ និងវារីវប្បកម្ម
- ការងារសាងសង់ដូចជារោងសិប្បកម្ម ឬរោងចក្រ និងការបំពាក់បរិក្ខារនានាសម្រាប់កែច្នៃវត្ថុធាតុដើម ដែលជាកសិផលក្នុងស្រុកឬ
- សកម្មភាពរួមគ្នានៃសកម្មភាពមួយចំនួន ឬទាំងអស់ដែលបានរៀបរាប់ខាងលើ។

## ៤.២ .គោលបំណងការធ្វើសម្បទានដីសេដ្ឋកិច្ច

- ដើម្បីអភិវឌ្ឍន៍សកម្មភាពប្រពលវប្បកម្ម និងកសិ-ឧស្សាហកម្មដែលតម្រូវឲ្យមានការវិនិយោគដើមទុនដំបូងក្នុងអត្រាខ្ពស់ និងកម្រិតសមស្រប។
- ដើម្បីសម្រេចបាននូវការព្រមព្រៀងមួយចំនួនជាក់លាក់ពីអ្នកវិនិយោគ សម្រាប់ការអភិវឌ្ឍដីក្នុងលក្ខណៈសមស្រប និងប្រកបដោយចីរភាពដោយផ្អែកលើផែនការប្រើប្រាស់ដីនៃតំបន់នោះ។
- ដើម្បីបង្កើតភាពមានការងារធ្វើនៅជនបទក្នុងក្របខណ្ឌនៃការធ្វើប្រពលវប្បកម្មនិង ការធ្វើឲ្យកាលានុវត្តភាពនៃការរកស៊ីចិញ្ចឹមជីវិតមានលក្ខណៈសម្បូរណ៍បែប និងក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងធនធានធម្មជាតិតាមប្រព័ន្ធអេកូឡូស៊ីសមស្រប។
- ដើម្បីលើកទឹកចិត្តរាល់ការវិនិយោគក្នុងគម្រោងសម្បទានដីសេដ្ឋកិច្ច និង
- បង្កើតចំណូលរដ្ឋ ឬចំណូលខេត្តក្រុង ឃុំសង្កាត់តាមរយៈការប្រមូលថ្លៃប្រើប្រាស់ដី ពន្ធ និងកម្រៃលើសេវាពាក់ព័ន្ធ។

## ៤.៣ .លក្ខខណ្ឌសម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច

សម្បទានដីសេដ្ឋកិច្ច អាចត្រូវបានផ្តល់ឲ្យចំពោះតែដីដែលមានលក្ខណវិនិច្ឆ័យទាំង ៥ ដូចខាងក្រោម ៖

1. ដីដែលត្រូវបានចុះបញ្ជី និងធ្វើចំណាត់ថ្នាក់ថាជាដីឯកជនរបស់រដ្ឋស្របតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ និងអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឬអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។
2. ដីដែលមានផែនការប្រើប្រាស់ដី អនុម័តដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ហើយការប្រើប្រាស់មានលក្ខណៈស្របទៅតាមផែនការនោះ។
3. ដីដែលបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមចំពោះការប្រើប្រាស់និងការអភិវឌ្ឍន៍ដីសម្រាប់គម្រោងសម្បទាន។
4. ដីដែលមានដំណោះស្រាយ ចំពោះបញ្ហាតាំងទីលំនៅថ្មីស្របតាមក្របខ័ណ្ឌគតិយុត្តិនិងនីតិវិធីជាធរមាន។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវធានាថាមិនមានការបង្ខំឲ្យធ្វើការតាំងទីលំនៅថ្មី ដោយគ្មានការស្ម័គ្រចិត្តពីអ្នកកាន់កាប់ដីស្របច្បាប់ និងត្រូវធានាចំពោះការគោរព សិទ្ធិមានច្រកចេញចូលទៅកាន់ដីឯកជន។
5. ដីដែលមានការពិគ្រោះយោបល់ជាសាធារណៈអំពីគម្រោង ឬសំណើសម្បទានដីសេដ្ឋកិច្ចជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលនៅក្នុងតំបន់។

*<u>កំណត់សំគាល់</u> ៖ ការពិគ្រោះយោបល់ជាសាធារណៈ ដែលអាចទទួលស្គាល់ថាត្រឹមត្រូវបាន និងមានប្រសិទ្ធិផល លុះត្រាតែ គោរពនូវគោលការណ៍ដូចខាងក្រោម ៖*

- *ប្រជាពលរដ្ឋមូលដ្ឋានដែលអាចយល់បានពីគំរោងសម្បទានដីសេដ្ឋកិច្ច*
- *ប្រជាពលរដ្ឋមូលដ្ឋាន អាចមានសមត្ថភាពក្នុងការវិភាគ និងជជែកពិភាក្សាពីគំរោងសម្បទាន ដីសេដ្ឋកិច្ច*
- *ប្រជាពលរដ្ឋមូលដ្ឋាន អាចមានសិទ្ធិសំរេចយល់ព្រម ឬមិនយល់ព្រម មានការចូលរួមពីប្រជាពលរដ្ឋមូលដ្ឋាន*

# ត្រូវមានការចូលរួមពីប្រជាពលរដ្ឋ



*ប្រជាពលរដ្ឋចូលរួមក្នុងវេទិកាសាធារណៈមួយរបស់ម.ស.ម.ក នៅខេត្តកំពង់ស្ពឺឆ្នាំ២០១០*

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា (ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ) មានភារកិច្ចទទួលខុសត្រូវក្នុងការរៀបចំការពិគ្រោះយោបល់ជាសាធារណៈជាមួយអាជ្ញាធរដែនដី និងតំណាងប្រជាពលរដ្ឋមូលដ្ឋានក្រោយពីទទួលបានឯកសារលំអិតនៃគម្រោងសម្បទាន

ដីសេដ្ឋកិច្ច។ ក្រុមប្រឹក្សាឃុំសង្កាត់ ដែលសម្បទានដីតាំងនៅមានសិទ្ធិពិនិត្យ និងផ្តល់យោបល់ក្នុងរយៈពេលយ៉ាងច្រើន ២៨ថ្ងៃនៃថ្ងៃធ្វើការគិតពីថ្ងៃដែលក្រុមប្រឹក្សាឃុំសង្កាត់បានទទួលសំណៅឯកសារលំអិតនៃគម្រោងសម្បទានដីសេដ្ឋកិច្ច ដែលក្រសួងកសិកម្ម និងរុក្ខប្រមាញ់បានបញ្ជូនមកឲ្យ។ ក្រសួងកសិកម្ម និងរុក្ខប្រមាញ់ត្រូវពិចារណាលើមតិយោបល់របស់ក្រុមប្រឹក្សាឃុំសង្កាត់ពាក់ព័ន្ធ។ ក្នុងករណីបដិសេធយោបល់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្តល់ហេតុផលច្បាស់លាស់។

## ៤.៤ .ការដកហូត និងការកាត់បន្ថយសម្បទានដីសេដ្ឋកិច្ច

សម្បទានដីសេដ្ឋកិច្ចអាចត្រូវបានរដ្ឋដកហូតយកវិញ ឬមោឃភាព ឬកាត់បន្ថយទំហំគឺផ្អែកតាមករណីដូចខាងក្រោម ៖

- សម្បទានដី អាចមានទំហំច្រើនបំផុតត្រឹមតែ១០០០០ហិចតា(មួយម៉ឺនហិចតា)។ សម្បទានដីដែលសំរេច ហើយមានទំហំលើសពីទំហំកំណត់ខាងលើជាកម្មវត្ថុនៃការកាត់បន្ថយ។
- ចំពោះសម្បទានដីលើសពី ១០០០០ (មួយម៉ឺន) ហិចតា ត្រូវបញ្ជាក់អំពីការស្ម័គ្រចិត្តកាត់បន្ថយទំហំដីដោយសម្បទានិក ឬត្រូវធ្វើការចរចាដើម្បីកាត់បន្ថយ ឬហេតុផលចាំបាច់សម្រាប់ការលើកលែងការកាត់បន្ថយសម្បទានដី។ ការជ្រើសរើសដីសម្រាប់កាត់បន្ថយត្រូវបញ្ចូលផ្នែកដែលមានទំនាស់ផ្នែក ដែលមិនទាន់បានកាប់ឆ្ការកាប់ឆ្ការ ផ្នែកដែលមិនទាន់បានអភិវឌ្ឍន៍ និងផ្នែកដែលជាដីសាធារណៈរបស់រដ្ឋ។
- លេខាធិការដ្ឋានបច្ចេកទេស សម្បទានដីសេដ្ឋកិច្ចក្នុងក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទមានតួនាទីផ្តល់យោបល់ និងធ្វើសេចក្តីបញ្ជាក់អំពីមូលហេតុនៃការកាត់បន្ថយដីសម្បទានសេដ្ឋកិច្ចដែលលើសទំហំដូចរៀបរាប់ខាងលើ។
- ការចេញលិខិតសម្បទានដីច្រើនកន្លែងឲ្យបុគ្គលតែម្នាក់ ឬឲ្យនីតិបុគ្គលច្រើន(ដូចជាក្រុមហ៊ុនច្រើន) តែគ្រប់គ្រងដោយរូបវន្តបុគ្គល (ម្ចាស់តែម្នាក់) ឬនីតិបុគ្គល (ក្រុមហ៊ុន)ដដែលៗ ដែលមានទំហំសរុបធំជាង១០០០០ (មួយម៉ឺន) ហិចតាត្រូវបានហាមឃាត់។
- រយៈពេលនៃសម្បទានដីត្រូវកំណត់ ៩៩ ឆ្នាំយ៉ាងច្រើនគឺមិនអាចលើសពីនេះបានទេ។
- រាល់សម្បទានដីសំរាប់ដំណាំឧស្សាហកម្ម ត្រូវចាប់ផ្តើមធ្វើអាជីវកម្មក្នុងរយៈពេល ១២ ខែ បន្ទាប់ពីការផ្តល់សម្បទាន បើមិនដូច្នោះទេនឹងត្រូវទុកជាមោឃៈ។

- រាល់សម្បទានដីដែលបានផ្ដល់ឲ្យមុនច្បាប់នេះចូលជាធរមាន ហើយមិនបានធ្វើអាជីវកម្មចាប់ពី ១២ ខែ ឡើងទៅគិតពីថ្ងៃដែលច្បាប់នេះចូលជាធរមានត្រូវទុកជាមោឃៈ ប្រសិនបើការខកខានមិនបានធ្វើអាជីវកម្មនោះដោយពុំមានមូលហេតុត្រឹមត្រូវ។
- រាល់ការមិនបានបំពេញកិច្ចតាមសៀវភៅបន្ទុកដោយសម្បទានិក នាំឲ្យមានការដកហូតសម្បទាន។
- ការផ្ដល់សម្បទានដែលមិនគោរពតាមលក្ខខណ្ឌទាំង ៥ នៃការផ្ដល់សម្បទាននាំឲ្យមានការដកហូត។

ដូច្នេះ សម្បទានដីសេដ្ឋកិច្ចនេះ ត្រូវដកហូតដោយសេចក្ដីសំរេចរបស់រដ្ឋបាល (រដ្ឋាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា) ក្នុងករណីលក្ខខណ្ឌច្បាប់ដូចបានរៀបរាប់ខាងលើមិនត្រូវបានគោរពដោយសម្បទានិក។ ហើយសម្បទានដីអាចត្រូវបានទុកជាមោឃៈដោយតុលាការដែរកាលបើ សម្បទានិកមិនគោរពដោយទ្បែកដែលមានចែងក្នុងកិច្ចសន្យា។

## ៤.៥ .យន្តការដាក់ពាក្យបណ្ដឹងទាក់ទងការផ្ដល់សម្បទានដីសេដ្ឋកិច្ច

ប្រជាពលរដ្ឋដែលទទួលរងគ្រោះអំពីការផ្ដល់សម្បទានដីសេដ្ឋកិច្ចអាចដាក់ពាក្យបណ្ដឹងទៅតាមស្ថាប័នដូចជា ៖

- ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ (ពាក្យបណ្ដឹងដាក់ទៅលេខាធិការដ្ឋានបច្ចេកទេសនៃក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ)
- តុលាការ (ពាក្យបណ្ដឹងដាក់ទៅសាលាដំបូងខេត្ត ក្រុង ដែលសម្បទានដីសេដ្ឋកិច្ចតាំងនៅ)
- អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី (ពាក្យបណ្ដឹងដាក់ទៅអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី)

## ៤.៦ .របៀបសរសេរពាក្យបណ្តឹង

**យន្តការដោះស្រាយទំនាស់ដីធ្លីចុងក្រោយបង្អស់នៅក្នុង ប្រទេសកម្ពុជាបច្ចុប្បន្នគឺតុលាការ**



### ៤.៦.១ .របៀបសរសេរពាក្យបណ្ដឹងទៅគណៈកម្មការសុរិយោដី

**គំរូពាក្យបណ្ដឹង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្ដឹង**

យើងខ្ញុំជាប្រជាពលរដ្ឋដែលមានឈ្មោះដូចខាងក្រោម៖

១. ..................អាយុ........ឆ្នាំ...........សញ្ជាតិ.........
២. ..................អាយុ........ឆ្នាំ...........សញ្ជាតិ.........
៣. ..................អាយុ........ឆ្នាំ...........សញ្ជាតិ.........

ទីលំនៅភូមិ.....................ឃុំ/សង្កាត់..................ស្រុក/ខណ្ឌ...................ខេត្ត/ក្រុង...........។

**សូមគោរពជូន**

**លោកប្រធានគណៈកម្មការសុរិយោដីស្រុក.............ខេត្ត......................**

**កម្មវត្ថុ ៖** សុំប្ដឹងពីក្រុមហ៊ុនឈ្មោះ....................ដែលបានឈូសឆាយកំទេចផ្ទះ និងរំលោភមកលើដីរបស់យើងខ្ញុំ។

តបតាមកម្មវត្ថុខាងលើ យើងខ្ញុំមានកិត្តិយសសូមជំរាបលោកប្រធានមេត្តាជ្រាបថា យើងខ្ញុំទាំងអស់គ្នាបានមករស់នៅក្នុងភូមិ......ឃុំ.........ខេត្ត........តាំងពីឆ្នាំ.........ដោយមានលិខិតបញ្ជាក់ពីការកាន់កាប់ដីពីអាជ្ញាធរ................។ យើងខ្ញុំទាំងគ្នាបានកាន់កាប់និងធ្វើស្រែចំការលើដីនោះរហូតមកដោយពុំមានការរំខានអ្វីឡើយ។ ប៉ុន្តែនៅថ្ងៃទី...ខែ....ឆ្នាំ...... ទើបមានក្រុមហ៊ុនមួយឈ្មោះ........................បានអះអាងថាជាដីរបស់ខ្លួន។ នៅថ្ងៃទី......ខែ ឆ្នាំ......ក្រុមហ៊ុននេះបានធ្វើការឈូសឆាយកំទេចផ្ទះសម្បែងចំនួន....ខ្នង និងដំណាំរបស់ប្រជា-ពលរដ្ឋយើងខ្ញុំលើដីចំនួន..........ហិកតា នៅចំណុច......ភូមិ.........ឃុំ.........ស្រុក........ខេត្ត ........។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាជួយចាត់វិធានស៊ើបអង្កេតការឈូសឆាយរបស់ក្រុមហ៊ុនដោយកំទេចផ្ទះ និងរំលោភមកលើដីរបស់យើងខ្ញុំ និងដោះស្រាយបញ្ចប់បញ្ហានេះឲ្យយើងខ្ញុំដោយក្តីអនុគ្រោះ។

សូមលោកប្រធាន មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីយើងខ្ញុំ។

ធ្វើនៅខេត្ត……….. ថ្ងៃទី...................ខែ..................ឆ្នាំ.................

ហត្ថលេខា ឬស្នាមមេដៃស្តាំអ្នកប្តឹង

ឈ្មោះ.................................. ឈ្មោះ....................................ឈ្មោះ..............................

ភ្ជាប់មកជាមួយនូវ ៖

១).....................................................................

២) ....................................................................

## ៤.៦.២ .របៀបសរសេរពាក្យបណ្តឹងទៅតុលាការ

**គំរូពាក្យបណ្តឹង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚៚✵៛៛

**ពាក្យបណ្តឹង**

យើងខ្ញុំជាប្រជាពលរដ្ឋដែលមានឈ្មោះដូចខាងក្រោម៖

១. ..................អាយុ........ឆ្នាំ...........សញ្ជាតិ.........

២. ..................អាយុ........ឆ្នាំ...........សញ្ជាតិ.........

៣. ..................អាយុ........ឆ្នាំ...........សញ្ជាតិ.........

ទីលំនៅភូមិ.....................ឃុំ/សង្កាត់..................ស្រុក/ខណ្ឌ...................ខេត្ត/ក្រុង...........។

**សូមគោរពជូន**

**លោកព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត**…………………………………..

**កម្មវត្ថុ ៖** សុំប្តឹងពីក្រុមហ៊ុនឈ្មោះ....................ពីបទ "បំផ្លេចបំផ្លាញ និងរំលោភអចលនវត្ថុស្របច្បាប់របស់បុគ្គល"។

តបតាមកម្មវត្ថុខាងលើ យើងខ្ញុំមានកិត្តិយសសូមជំរាបជូនលោកព្រះរាជអាជ្ញាមេត្តាជ្រាបថា យើងខ្ញុំទាំងអស់គ្នាបានមករស់នៅក្នុងភូមិ…….ឃុំ………ខេត្ត……….តាំងពីឆ្នាំ.........ដោយមានលិខិតបញ្ជាក់ពីការកាន់កាប់ដីពីអាជ្ញាធរ…………។ យើងខ្ញុំទាំងគ្នាបានកាន់កាប់ និងធ្វើស្រែចំការលើដីនោះរហូតមកដោយពុំមានការរំខានអ្វីឡើយ។ ប៉ុន្តែនៅថ្ងៃទី......ខែ….ឆ្នាំ…….ទើបមានក្រុមហ៊ុនមួយឈ្មោះ........................បានអះអាងថាជាដីរបស់ខ្លួន។ នៅថ្ងៃទី……ខែ……ឆ្នាំ.........ក្រុមហ៊ុននេះបានធ្វើការឈូសឆាយកំទេចផ្ទះសម្បែងចំនួន……ខ្នង និង

ដំណាំរបស់ប្រជាពលរដ្ឋយើងខ្ញុំលើដីចំនួន…………ហិកតា នៅចំណុច……ភូមិ………ឃុំ………
ស្រុក…….ខេត្ត……..។

អាស្រ័យហេតុនេះទើបយើងខ្ញុំ សូមប្ដឹងមកលោកព្រះរាជអាជ្ញាមេត្តាជួយចាត់វិធានការស្រាវជ្រាវ ចោទប្រកាន់ និងផ្ដន្ទាទោសក្រុមហ៊ុនខាងលើតាមច្បាប់។

ក្នុងករណីនេះយើងខ្ញុំប្ដឹងទាមទារ ៖

- ចោទប្រកាន់ និងផ្ដន្ទាទោសក្រុមហ៊ុនខាងលើតាមច្បាប់ពីបទ "បំផ្លេចបំផ្លាញ និងរំលោភលើអចលនវត្ថុស្របច្បាប់របស់បុគ្គល"។
- ទាមទារសំណងជម្ងឺចិត្តពីក្រុមហ៊ុនខាងលើក្នុងម្នាក់ៗចំនួន……………………..

សូមលោកព្រះរាជអាជ្ញា មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីយើងខ្ញុំ។

ធ្វើនៅខេត្ត……….. ថ្ងៃទី.................. ខែ................. ឆ្នាំ................

ហត្ថលេខា ឬស្នាមមេដៃស្ដាំអ្នកប្ដឹង

ឈ្មោះ.................................. ឈ្មោះ....................................ឈ្មោះ..............................

ភ្ជាប់មកជាមួយនូវ ៖

១).......................................................................

២) .......................................................................